Box 13 fn 150

27 MIN

PAGE 1
RADIO PROGRAMME SCRIPT # 139 K.
PRODUCER: SONG SOVANN
EDITED BY V.TSIORKO & STEVEN S.PAK
DURATION: 30:00
DATE

SAMREUH ~~RICHOR~~:

អស់លោកអ្នកនាងស្ដាប់ជាទីមេត្រី ! ជាបន្តទៅទៀតនេះសូមអញ្ជើញអស់លោកអ្នកនាងស្ដាប់ព័ត៌មានសំខាន់ៗ និងសេចក្ដីរាយការណ៍ស្ដីអំពីស្ថានភាពនៃជនភៀសខ្លួន និងជនផ្លាស់ប្ដូរទីកន្លែងកម្ពុជា ហើយលោកអ្នកនាងនិងបានស្ដាប់បទចំរៀងខ្មែរដ៏ពិរោះៗទៀតផង។

« ភ្លេងខ្លីៗ »

THIDA:

ការប្រគុំតន្ត្រីអន្តរជាតិរបស់អ៊ុនតាក់ ដើម្បីរំលឹកបុណ្យខួបលើកទីមួយ នៃថ្ងៃមកដល់របស់អ៊ុនតាក់នៅក្នុងប្រទេសកម្ពុជានោះ និងប្រារព្ធធ្វើការប្រគុំតន្ត្រីមួយនៅភ្នំពេញ នាថ្ងៃអាទិត្យ ទី ១៤ ខែមីនា ឆ្នាំ ១៩៩៣ ក្នុងតារាងបាល់បោះខាងក្នុង នៃពហុកីឡដ្ឋានជាតិអូឡាំពិក។ ការសំដែងនោះ និងចាប់ផ្ដើមនៅវេលាម៉ោង ១៤ និង ៣០ ពេលល្ងាច។

RICHOR:

ការប្រគុំតន្ត្រីអន្តរជាតិនេះ និងមានការចូលរួមដោយអ្នកសំដែង ដែលមកពីប្រទេសបង់ក្លាដេស ឥណ្ឌា ឥណ្ឌូណេស៊ី ជប៉ុន និងប៉ាគីស្ថាន ព្រមទាំងមានច្រៀងចំរៀងសំដែងរបាំជាតិ សិល្បៈកាយ វប្បធម៌ ការសំដែង ការហ្វឹកហ្វឺនសំរាប់ពិធីបុណ្យ។ នៅពេលជាមួយគ្នានោះដែរ និងមានការប្រគុំតន្ត្រី និងការសំដែងដោយក្រុមតន្ត្រីយោធាផងដែរ។

THIDA:

ការប្រគុំតន្ត្រីនោះ និងត្រូវបានគេបើកចំហរ សំរាប់ការទស្សនាទូទៅ ក្នុងសំបុត្រមួយតម្លៃ ១,០០០រៀល និងតម្លៃ ៥ ដុល្លារអាមេរិក ចំពោះទស្សនិកជនណា ដែលចង់កក់កៅអីទុកជាមុននោះ។ ហើយប្រាក់ចំណូលដែលរកបានមកពីការសំដែងនេះ និងប្រគល់ជូនទៅឲ្យអង្គការយូនីសេហ្វ សំរាប់ទិញក្រដាស ដើម្បីធ្វើការបោះពុម្ពសៀវភៅមើល ចែកជូនដល់សិស្សានុសិស្ស និងកុមារា កុមារី កម្ពុជា ។

RICHOR:

សំបុត្រនិងមានដាក់លក់ នៅការិយាល័យ អង្គការយូនីសេហ្វ នៅភ្នំពេញ ដែលមានអាសយដ្ឋាន ផ្ទះលេខ-១១ ផ្លូវ ៧៥ សង្កាត់ស្រះចក ភ្នំពេញ។

« ភ្លេងខ្លី ៗ.......................................................»។

SAKHAN ~~THIDA~~:

សិក្ខាសាលាស្តីពីការកែទម្រង់សេដ្ឋកិច្ចកម្ពុជា ត្រូវបានគេធ្វើឡើងនៅសាលមហោស្រព ទន្លេបាសាក់ កាលពីព្រឹកថ្ងៃទី ៨ កុម្ភៈ កន្លងទៅនេះ។

សិក្ខាសាលាធ្វើឡើង ក្នុងគោលបំណងឆ្លុះបញ្ចាំងឲ្យឃើញ នូវមូលហេតុដែលធ្វើឲ្យសេដ្ឋកិច្ចជាតិ ធ្លាក់ចុះដុនដាប និងគោលបំណងជួយដាស់សតិកូនខ្មែរ ឲ្យភ្ញាក់រលឹកក្រោកឈរឡើង ដោយធ្វើការសំរេចចិត្តជាដាច់ខាត ដើម្បីចាប់ផ្តើមកាន់កាប់ភ្លាម នូវសេដ្ឋកិច្ចជាតិ ដែលជាការអាចជួយស្រោចស្រង់ និងកសាងជាតិខ្មែរ ឲ្យមានវិបុលភាព កិត្តិយស ភាពថ្លៃថ្នូរ និងភាពខ្ពង់ខ្ពស់ ហើយនិងអាចជួយគ្រួសារ ឲ្យមានជីវភាពធូរធារ ប្រកបដោយសុភមង្គលទៀតផង។

RICHOR:

លោក ហេងគីមអ៊ី អតីតអគ្គនាយកធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងទសវត្សនៃឆ្នាំ១៩៦០ បច្ចុប្បន្នអ្នកជំនាញការ នៃអង្គការរូបិយវត្ថុអន្តរជាតិ និងជាអភិបាលរង នៃធនាគារពិភពលោក បានមានប្រសាសន៍ថា ៖ ប្រទេសជាតិនិមួយៗ អាចនឹងរីកចំរើនលូតលាស់ឡើង យ៉ាងស្ថិតស្ថេរ និងមានសន្តិភាពក្នុងសង្គមបាន លុះត្រាតែ « ប្រជាជនរបស់ប្រទេសនោះ កាន់កាប់សេដ្ឋកិច្ចរបស់ខ្លួននៅគ្រប់តំបន់ ដោយដៃខ្លួនឯងផ្ទាល់ »។

SAKHAN ~~THIDA~~:

លោក ហេងគីមអ៊ី បានបន្តទៀតថា ៖ មានឧបសគ្គ ២ ដែលធ្វើឲ្យសេដ្ឋកិច្ចជាតិយើងមិនរីកចំរើន។ ទី ១ គឺដោយសារប្រទេសយើងនៅមានសង្គ្រាម ជាមូលហេតុចំបង ព្រោះមានអ្នកខំកសាង ហើយជាមួយនេះ ក៏មានអ្នកចូលមកធ្វើការបំផ្លាញដែរ មិនអាចរីកចំរើនបានទេ។ ទី ២ ការកែទម្រង់សេដ្ឋកិច្ចក្នុងប្រទេស កំពុងតែអនុវត្តន៍បណ្តើរ ហើយធ្វើការដកពិសោធន៍បណ្តើរ គ្មានគោលដៅច្បាស់លាស់ទេ សូម្បីតែពិភពលោក ក៏មិនទាន់មានបទពិសោធន៍ ក្នុងការកែទម្រង់សេដ្ឋកិច្ចនេះដែរ ។ សេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ននេះ កំពុងធ្លាក់ចុះដុនដាបយ៉ាងខ្លាំង ពិសេសមួយទៀត គឺពួកបរទេស មិនមានការស្មោះត្រង់ និងជួយខ្មែរ

ដោយស្មោះនោះទេ។ ឧទាហរណ៍ ការសន្យាផ្តល់ជំនួយអភិវឌ្ឍន៍ប្រទេសកម្ពុជា មកដល់ពេលនេះហើយ យើងមិនទាន់បានអ្វីបន្តិចបន្តួចនៅឡើយទេ។

RICHOR:

លោក ហេងតឹមអ៊ី បានបញ្ជាក់ទៀតថា ៖ « ភាពវិបុលភាព ភាពសំបូរសប្បាយ មិនអាចកើតមានឡើងបាន ដោយសារតែការសរសេរនៅលើក្រដាស ឬពឹងផ្អែកទាំងស្រុង ទៅលើជំនួយបរទេសនោះទេ គឺផ្ទុយពីនេះទៅវិញ ភាពទាំងអស់នេះ អាចមានរូបរាងឡើងបាន លុះត្រាតែប្រជាជនខ្មែរទាំងអស់គ្នាក្រោកឈរឡើង ហើយប្រើកម្លាំងដែលមាន ដើម្បីប្រកបនូវកិច្ចការដោយជំនាញ ដោយប្រើនូវបច្ចេកទេសត្រឹមត្រូវ ដោយប្រើការរៀបចំ ប្រកបដោយប្រសិទ្ធិភាព និងដោយប្រាជ្ញាវាងវៃ ក្នុងការរកទទួលទាន»។

~~SAKHAN~~ SAMROUT

THIDA:

អស់លោកអ្នកនាងទើបនិងបានស្តាប់ពត៌មានសំខាន់ ៗ ដែលទាក់ទងអំពីការប្រគុំតន្ត្រីអន្តរជាតិរបស់ អ៊ុនតាក់ ហើយនិងអំពីសិក្ខាសាលា ស្តីពីការកែទម្រង់សេដ្ឋកិច្ចកម្ពុជា។ ជាបន្តទៅទៀតនេះ សូមអញ្ជើញអស់លោកអ្នកនាង រីករាយកំសាន្តជាមួយបទចំរៀងខ្មែរមួយបទក្រោមចំណងជើងថា«.........................................»ច្រៀងដោយ..................................។

SAMRECH

~~RICHOR~~:

អស់លោកអ្នកនាងស្តាប់ជាទីមេត្រី! ជាបន្តទៅទៀតនេះ សូមអញ្ជើញអស់លោកអ្នកនាងស្តាប់សេចក្តីរាយការណ៍ ស្តីអំពីស្ថានភាពនៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា។

THARY:

ជាភាគមួយ នៃដំណោះស្រាយនយោបាយរួមនោះ ចាំបាច់ត្រូវផ្តល់ជំនួយឧបត្ថម្ភគ្រប់បែបយ៉ាងដល់ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ក៏ដូចជាដល់បណ្តាប្រទេស ដែលផ្តល់ជំរកជាបណ្តោះអាសន្ន និងប្រទេសជាប្រភពដើម នៃជនភៀសខ្លួន ដើម្បីសំរួលដល់ការវិលត្រឡប់ ដោយស្ម័គ្រចិត្ត ដោយសន្តិវិធី និងមានរបៀបរៀបរយ របស់ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជាគ្រប់រូប ។ គេក៏ត្រូវធានាវ៉ាបរងផងដែរ ថានិងមិនមានបញ្ហាសេសសល់ណាឡើយ សំរាប់ប្រទេសដែលផ្តល់ជំរកបណ្តោះអាសន្ននោះ។ ហើយប្រទេសដែលជាប្រភពដើមនៃជនភៀសខ្លួន ដោយមានការទទួលខុះត្រូវ ចំពោះប្រជាជនរបស់ខ្លួន

ផ្លាស់ ត្រូវទទួលយកការវិលត្រឡប់របស់ពួកគេ នៅពេលណាមានលក្ខណៈអំណោយផល ហើយនោះ។

THARY:

លោក ស្រោមសទ្ធា ជាជនភៀសខ្លួនខ្មែរមួយរូប ដែលទើបតែធ្វើមាតុភូមិនិវត្តន៍ ពីជំរំជនភៀសខ្លួនខ្មែរ SITE 2 ព្រំដែនខ្មែរ-ថៃ កាលពីថ្ងៃទី ២៣ មករា ១៩៩៣ កន្លងមកថ្មីៗនេះ។ លោកមានកូន ៣ នាក់នៅក្នុងបន្ទុក។ ហើយស្រុកកំណើតរបស់លោកនៅភូមិ អូសទូក ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។

RITHY:

ក្រោយពីការរស់នៅ នៅក្នុងជំរំតាមព្រំដែនខ្មែរ-ថៃ អស់រយៈកាល ១៣ ឆ្នាំនោះមក លោកសទ្ធា ក៏បានធ្វើមាតុភូមិនិវត្តន៍ ជាមួយគ្រួសារព្រមទាំងកូនតូចៗ ដោយជ្រើសរើសយកចំណុចទី ៣ នៃការធ្វើមាតុភូមិនិវត្តន៍ ដែលហៅថា « OPTION C » ហើយគោលដៅដែលចុះនោះ នៅមណ្ឌលទទួលជនភៀសខ្លួន ទួលម្កាក់ ខេត្តបាត់ដំបង។

THARY:

ចំណុចទី ៣ នៃការធ្វើមាតុភូមិនិវត្តន៍នេះ ជនភៀសខ្លួនខ្មែរគ្រប់រូប ត្រូវបានទទួលប្រាក់ពីអង្គការ UNHCR ចំនួន ៥០ដុល្លារ អាមេរិក សំរាប់មនុស្សចាស់ក្នុងម្នាក់ ៗ ហើយ ២៥ ដុល្លារ សំរាប់ក្មេងដែលមានអាយុក្រោម ១២ ឆ្នាំ និងគ្រឿងសំភារៈប្រើប្រាស់ គ្រឿងសំភារៈសំណង់មួយចំនួន ព្រមទាំងម្ហូបអាហារសំរាប់ ៤០០ ថ្ងៃ ។

RITHY:

ត្រូវមានការគោរពទាំងស្រុងចំពោះសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន របស់ជនកម្ពុជាគ្រប់រូប រួមទាំងសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន របស់ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ដែលបានវិលត្រឡប់ទៅកាន់មាតុភូមិវិញផង ដោយទទួលស្គាល់ដល់សិទ្ធិរបស់ពួកគេ ដើម្បីរស់នៅដោយសន្តិភាព និងសន្តិសុខ ដោយគ្មានការសំឡុតគំហែង ឬបង្ខិតបង្ខំអ្វីទាំងអស់ ។ សិទ្ធិទាំងនោះនិងរួមមាន ក្នុងចំណោមសិទ្ធិដទៃទៀត សេរីភាពក្នុងការធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា សិទ្ធិជ្រើសរើសទីលំនៅដ្ឋាន និងប្រកបមុខរបរការងារ ហើយនិងសិទ្ធិក្នុងការមានកម្មសិទ្ធិ។

THARY:

លោក សមសទ្ធា បានមានប្រសាសន៍ថា៖ កាលពីដំបូង លោកបានជ្រើសរើសយកចំណុច សំរាប់ធ្វើមាតុភូមិនិវត្តន៍នៅមណ្ឌលទទួលជនភៀសខ្លួនទួលម្កាក់ ខេត្តបាត់ដំបង ដែលជាស្រុកកំណើតរបស់លោក តែដោយមកអំពីការស៊ើបសួររកបងប្អូនមិនទាន់បានឃើញ ទីបំផុត លោកក៏សំរេចចិត្តថា មកចុះនៅមណ្ឌលភ្នំពេញវិញ។ ហើយលោកក៏បានចុះឈ្មោះ សំរាប់ការបោះឆ្នោត ក្រោយពីការធ្វើមាតុភូមិនិវត្តន៍ តែពីរបីថ្ងៃប៉ុណ្ណោះ។

RITHY:

ក្រោយពីការសំណាក់នៅអស់មួយរយៈខ្លីនោះមក លោក សទ្ធា ក៏បានចេញពីមណ្ឌលទទួលជនភៀសខ្លួន តាមរយៈអង្គការ UNHCR ហើយបានជួបនិងកូនបង្កើតរបស់លោក ព្រមទាំងមិត្តភក្តិមួយចំនួន ដែលរស់នៅទីក្រុងភ្នំពេញ ដោយលោកមានប្រសាសន៍ថា ៖

SOUND BITE: « ចូលមកដល់ភ្នំពេញ ខ្ញុំមិនទាន់បានជួបសាច់សារលោហិតណា ក្រៅពីកូនបង្កើតរបស់ខ្ញុំ ដែលមានគ្រួសារនៅទួលគោកនោះទេ ហើយមិត្តភក្តិមួយចំនួនទៀត ដែលធ្វើដំណើរមកពី SITE 2 ដូចគ្នា ប៉ុន្តែគេមកមុន គេបានទទួលការងារពី អ៊ុនតាក់ នោះខ្លះ ហើយគេបានជួយឧបត្ថម្ភខ្ញុំបន្តិចបន្តួច តាមលទ្ធភាពរបស់គេ »។

THARY:

នៅក្នុងបរិយាកាស ដែលបង្ករលក្ខណៈជាភាតរភាព មិត្តភាព និងសុខដុមរមនា ព្រមទាំងសម្លឹងមើលឃើញទិដ្ឋភាពមួយ ដែលស៊ីចង្វាក់គ្នាជាមួយនិងកងទ័ព អ៊ុនតាក់ ក្នុងការស្វែងរកសន្តិភាពជូនកម្ពុជា ដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រកម្ពុជានោះ លោក សទ្ធា ក៏បានទទួលនូវការលើកទឹកចិត្តមួយកំរិត ជាងកាលនៅឯព្រំដែនខ្មែរ-ថៃ ដោយលោកមានប្រសាសន៍ថា ៖

SOUND BITE: « ខ្ញុំមានការរំភើបចិត្តយ៉ាងខ្លាំង ដោយបានឃើញមិត្តភក្តិមួយចំនួនមានការងារធ្វើ ដោយបានទទួលកំរៃផលគ្រប់គ្រាន់ រស់រានចិញ្ចឹមគ្រួសារ ហើយឃើញសភាពការណ៍នៅទីក្រុងភ្នំពេញ មានការសុខស្រួល ដោយគ្មានការភិតភ័យព្រួយបារម្ភអ្វី ដោយសារការឃុំគ្រងរបស់កងទ័ព អ៊ុនតាក់ ដែលចូលមកជួយថែរក្សាសុខសន្តិភាព ឲ្យប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសកម្ពុជា បាទ! »។

RITHY:

ដើម្បីធានាឲ្យមានបរិយាកាសនយោបាយអព្យាក្រឹត្យមួយ ក្នុងការសំរួលដល់ការបោះឆ្នោតទូទៅ ដោយសេរី និងត្រឹមត្រូវយុត្តិធម៌ នៅក្នុងប្រទេសកម្ពុជា នាពេលអនាគតដ៏ខ្លីខាងមុខនេះ លោក សទ្ធា ក៏បានមានប្រសាសន៍ថា ៖ លោកមានការទំនុកទុកចិត្តទាំងស្រុង ទៅលើអង្គការសហប្រជាជាតិ ព្រោះអង្គការនេះ ជាអង្គការពិភពលោក ហើយអាចសំរេចបានរាល់កិច្ចការទាំងអស់ ដែលមានចែងមនៅក្នុងច្បាប់អង្គការសហប្រជាជាតិនោះ។ លោកមានប្រ-សាសន៍ថា៖

SOUND BITE:« ខ្ញុំជឿថា អង្គការសហប្រជាជាតិ គឺជាអង្គការកំពូលមួយ នៅក្នុងពិភពលោក ដូច្នោះអ្វី ៗ ទាំងអស់ បើសិនជាអង្គការសហប្រជាជាតិបានសំរេច បានរៀបចំ ឬមានគោលបំណងចង់ធ្វើ ខ្ញុំជឿជាក់ថា ប្រាកដជាបានសំរេច ដូចគោលបំណងរបស់អង្គការសហប្រជាជាតិតែម្តង »។

THARY:

ម៉្យាងទៀត លោក សមសទ្ធា ហើយនិងបងប្អូនជនធ្វើមាតុភូមិនិវត្តន៍ខ្មែរមួយចំនួនទៀត ក៏មានការព្រួយបារម្ភដូចគ្នាដែរ អំពីស្ថានការណ៍នយោបាយប្រទេសកម្ពុជា ដូចជាកិច្ចព្រម-ព្រៀងសន្តិភាពនៅទីក្រុងប៉ារីស គ្រប់ភាគីនៅមិនទាន់បានគោរពឲ្យបានពេញលេញនៅឡើយទេ ហើយផ្នែកសន្តិសុខ និងសិទ្ធិមនុស្សក៏យ៉ាងនោះដែរ។ តែទោះជាយ៉ាងណាក៏ដោយ លោកនិងបងប្អូនជនធ្វើមាតុភូមិនិវត្តន៍ទាំងនោះ ក៏ដាក់ជំនឿទាំងស្រុង ទៅលើសមត្ថភាពរបស់ អ៊ុនតាក់ ដើម្បីរៀបចំប្រទេសកម្ពុជា ឲ្យបានសុខស្រួល ហើយក៏សូមសំណូមពរចំពោះអ៊ុនតាក់ ដោយមានប្រសាសន៍ថា ៖

SOUND BITE:« សូមសំណូមពរទៅលើមេដឹកនាំរបស់ អ៊ុនតាក់ ហើយនិងកងទ័ពរបស់អ៊ុន-តាក់ទាំងអស់ ថាខំធ្វើយ៉ាងណា មេត្តាជួយរកសុខសន្តិភាពឲ្យខ្មែរឲ្យបាន ហើយខំធ្វើយ៉ាងណាឲ្យមានសិទ្ធិមនុស្សគ្រប់គ្រាន់ និងសន្តិសុខបរិបូរនៅក្នុងសង្គមហ្នឹង ហើយធ្វើយ៉ាងណាឲ្យភាគីខ្មែរហ្នឹង បានស្រុះស្រួល មូលមតិគ្នាជាឯកឆន្ទ ដើម្បីស្ថាបនានាវាកម្ពុជា ឆ្ពោះទៅរកត្រើយសុខសាន្ត បាទ ! »

ពេជ្រ សារាត,

SOUND BITE:« ចាំ ! ខ្ញុំសូមសំណូមពរថា ធ្វើយ៉ាងណាឲ្យបោះឆ្នោតឲ្យមានយុត្តិធម៌ ហើយសន្តិភាព ខ្ញុំសប្បាយចិត្តណាស់ ជាពិសេសទៅទៀត ខ្ញុំចង់ឲ្យកងទ័ព អ៊ុនតាក់ ការពារឲ្យមានសន្តិភាព ហើយកន្លែងណាដែលមានមីន សូមឲ្យអង្គការ អ៊ុនតាក់ ហ្នឹងជួយដោះស្រាយផង»។

ស៊ឹម រិទ្ធី

SOUND BITE:«សំណូមពររបស់ខ្ញុំ គឺចង់បានតែសន្តិភាព ហេតុដូច្នោះ គ្រាន់តែថា ចង់ឲ្យតែកងទ័ពអន្តរជាតិ លៃយ៉ាងណា ឲ្យមានយុត្តិធម៌ នៅក្នុងស្រុកខ្មែរ ឲ្យមានសន្តិសុខគ្រប់យ៉ាងទាំងអស់»។

RITHY:

ចំណែកពូ សេងឡាយ ដែលមានអាយុ ៥៣ ឆ្នាំ មានកូន ៩ នាក់នៅក្នុងបន្ទុក ស្រុកកំណើតនៅភូមិ ជ្រោយស្ដៅ ឃុំជ្រោយស្ដៅ ស្រុកកោះធំ ខេត្តកណ្ដាល, ជាជនភៀសខ្លួនខ្មែរមួយរូប ដែលទើបតែធ្វើមាតុភូមិនិវត្តន៍ ពីជំរំ SITE 2 នៅពេលថ្មីៗនេះដែរ។ គោលបំណងចង់ទៅរស់នៅស្រុកកំណើតរបស់គាត់។

THARY:

ក្រោយពីការសំណាក់នៅឯជំរំព្រំដែនខ្មែរ-ថៃ អស់រយៈកាល ១៣ ឆ្នាំនោះមក លោកពូក៏បានធ្វើមាតុភូមិនិវត្តន៍ ដោយធ្វើដំណើរចូលមកមណ្ឌលទទួលជនភៀសខ្លួនភ្នំពេញ។ ក្រោយពីការធ្វើមាតុភូមិនិវត្តន៍នោះមក គាត់ក៏មានសេចក្ដីរំភើបចិត្តណាស់ ដោយបានជួបបងប្អូនសាច់សាលោហិតមួយចំនួន។ ហើយបន្ទាប់ពីការជួបជុំគ្នានោះមក គាត់ក៏មានទឹកមុខក្រៀម-ក្រមយ៉ាងខ្លាំង ដោយព្រួយបារម្ភអំពីស្ថានភាព នៃការរស់នៅរបស់គាត់ លោក ពូ មានប្រ-សាសន៍ថា ៖

SOUND BITE:« ខ្ញុំបាទចង់ទៅរស់នៅស្រុកកោះធំ តែសព្វថ្ងៃនេះ បើនិយាយរួម ខ្ញុំមិនទាន់បានកំណត់ថា ខ្ញុំរស់នៅកន្លែងណាទេ ដោយងាកទៅការខ្វះខាត ហើយងាកទៅខាងកិច្ចការអ្វីៗ មើលទៅខ្ញុំមិនអាចរស់នៅ ក្នុងពេលខាងមុខនេះទេ ខ្ញុំនិងធ្វើដំណើរទៅកន្លែងណាផ្សេងទៀត »។

RITHY:

នៅស្រុកកំណើតរបស់លោក ពូ គឺស្រុកកោះធំ លោក ពូ មិនសូវមានការសប្បាយចិត្ត និងការរស់នៅប៉ុន្មានទេ ដោយខ្លួនគាត់ផ្ទាល់មើលឃើញបរិយាកាសអាប់អួរពេក ដែលនាំឲ្យប៉ះពាល់ដល់ការរស់នៅរបស់គាត់ ដូចជាជីវភាពរបស់គាត់មានភាពដុនដាបច្រើន ដោយសារតែមានកូនច្រើន ហើយកន្លែងបង្ករបង្កើនផលក៏អតមានដែរ។ ហើយម្យ៉ាងទៀត លោកពូបានមានប្រសាសន៍ថា៖ ក៏ជះឥទ្ធិពលមកពីខាងក្រៅច្រើនណាស់ដែរ ដោយសារតែអនិកជនជាច្រើន បានចូលមកតាំងទីលំនៅ នៅក្នុងស្រុកនោះ។ មូលហេតុទាំងនេះហើយ ដែលជំរុញឲ្យគាត់ត្រូវសំរេចចិត្តថា ត្រូវដឹកកូនជញ្ជូនចៅ ទៅនៅឯខេត្តបាត់ដំបងវិញ ដើម្បីរកដីធ្លីសំរាប់ប្រកបរបរកសិកម្ម។

THARY:

និយាយរួម ក៏នៅក្នុងស្ថានភាពនៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជាទាំងអស់នោះដែរ លោកពូ សេងឡាយ ក៏មានសេចក្តីខ្វល់ខ្វាយយ៉ាងខ្លាំង ចំពោះជីវភាពនៃជនកម្ពុជាទាំងនោះ ដោយមានប្រសាសន៍ថា ៖

SOUND BITE:« ចំពោះជនភៀសខ្លួន ដែលត្រឡប់មកទឹកដីខ្មែរមួយដំណាក់កាលនេះ អ្នកមកមុន រយៈកាលពីខែ ៣ មក រហូតមក គឺថា វាមានសកម្មភាព គឺផុតអាណត្តិសំរាប់របប តែកាលណាវាផុតរបបហើយ វាមានការវេទនា ក្នុង ១០០ គឺថាវា វេទនាអស់៩០ហើយ ដូច្នេះបញ្ហាអស់ទាំងនេះ ត្រូវតែទាក់ទងទៅលើបញ្ហាសេដ្ឋកិច្ច »។

RITHY:

ទីបំផុត លោកពូ ក៏បានស្នើសុំ ឲ្យក្រុមអ្នកជំនាញការខាងផ្នែកសេដ្ឋកិច្ច គឺធ្វើយ៉ាងណាកុំទទួលយកផលិតផលពីខាងក្រៅច្រើនពេក ដែលនាំឲ្យផលិតផលក្នុងស្រុក មានការធ្លាក់ចុះដុនដាប ហើយជីវភាពប្រជាពលរដ្ឋ ប្រជាជន ក៏មានការធ្លាក់ចុះអនខ្សោយ តាមលំដាប់នោះដែរ លោក ពូ មានប្រសាសន៍ថា ៖

SOUND BITE:« សំណូមពររបស់ខ្ញុំគឺថា ចង់ឲ្យអស់លោកដែលមានសមត្ថភាព ខាងសេដ្ឋកិច្ច គឺថា សូមជួយដោះស្រាយប្រជាជនខ្មែរ ដែលធ្វើផលបានហើយ ទាក់ទាញផលនោះឲ្យបានគ្រប់គ្រាន់ កុំឲ្យមានការខ្វះខាតទៅដល់ប្រជាជន ដែលគ្នាខំធ្វើនោះ កាលណាភោគផលទាំងអស់ត្រូវទាក់ទាញមកទិញឲ្យអស់ពីប្រជាពលរដ្ឋ ឲ្យអស់ពីប្រជាជនទៅ ដូច្នេះបញ្ហាអស់ទាំង-

នេះ វាមិនប៉ះពាល់អីតទៅទៀត»។

SAMRETH

~~SAKHAN~~ ~~RITHY~~:

អស់លោកអ្នកនាងស្តាប់ជាទីមេត្រី ! ដើម្បីនិងកំដរអារម្មណ៍ វិទ្យុយើងសូមជូនចំរៀងខ្មែរមួយបទ ដែលមានចំណងជើងថា«..............................»

បទចំរៀង:..........................................................................។

THARY:

SAKHAN

អស់លោកអ្នកនាងស្តាប់ជាទីមេត្រី ! អំពីស្ថានភាពនៃជនភៀសខ្លួននិងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ដែលបានធ្វើមាតុភូមិនិវត្តន៍ ក៏បានជួបប្រទះនិងការលំបាកខ្លះៗដែរ ខាងផ្នែកជីវភាពនិងការរស់នៅ ដូចជាទីកន្លែងសំរាប់សង់ផ្ទះសម្បែង ដីសំរាប់ដាំដំណាំ និងផ្សេងៗទៀត ដូចជាលោក ស៊ីហ្សឹយូ វីយេរ៉ាដឺមិលទ្យ ប្រធានស្នងការជាន់ខ្ពស់ របស់អង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន ហៅកាត់ថា យូអិនអេកស៊ីអា បានមានប្រសាសន៍ថា ជនភៀសខ្លួនដែលធ្វើមាតុភូមិនិវត្តន៍ និងអ្នកដែលជួយឧបត្ថម្ភពួកគេនោះ កំពុងតែប្រឈមមុខនឹងបញ្ហាចំបងបីយ៉ាងគឺ ទី១ តម្រូវការរបស់រដ្ឋអំណាច នៅក្នុងរដ្ឋធានី នឹងតាមតំបន់ជនបទរបស់គណៈបក្សទាំង ៤ ក្នុងការជួយឧបត្ថម្ភអង្គការ យូអិនអេកស៊ីអា បន្តទៅទៀត ដើម្បីផ្តល់ពត៌មាន នឹងការបែងចែកដីដាំដំណាំ ដល់ជនធ្វើមាតុភូមិនិវត្តន៍ ដើម្បីធ្វើកសិកម្ម ។

ទី ២ តម្រូវការក្នុងការសំអាតមីននៅលើផ្ទៃដី ឲ្យបានច្រើនទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ពីព្រោះការងារនេះកំពុងត្រូវគេអនុវត្តន៍ នៅក្នុងស្រុកស៊ីសូផុន នឹងខេត្តសៀមរាប ។

ទី ៣ ការមិនគោរពបទឈប់បាញ់គ្នា ដែលបានបណ្តេញ ជនធ្វើមាតុភូមិនិវត្តន៍ចេញពីលំនៅស្ថានថ្មីរបស់ពួកគេ ។

SOPHEAP

Rithy

~~RITHY~~:

លោកបានមានប្រសាសន៍ទៀតថា ៖ យើងត្រូវបំពេញការងារថែមទៀត មុននិងយើងចាត់ទុកថា ជនភៀសខ្លួនដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានប្រមូលផ្តុំរួចរាល់ហើយនោះ។ ក្រៅពីការលើកឡើងបញ្ហាជាក់ស្តែង ពីដីធ្លី ភាពរាំងស្ងួត និងគ្រោះថ្នាក់ដោយសារគ្រាប់មីននោះ លោកក៏បានអះអាងថា មានអ្នកខ្លះនិយាយថា អង្គការ UNHCR កំពុងតែរលាស់ដៃចេញពីបញ្ហានេះ។

~~SAKH~~ANTHARY: THARY

ការធ្វើមាតុភូមិនិវត្តន៍ មិនត្រឹមតែជាដំណោះស្រាយត្រឹមត្រូវសមហេតុសមផល ចំពោះបញ្ហាជនធ្វើមាតុភូមិនិវត្តន៍តែប៉ុណ្ណោះទេ តែស្ថិតនៅក្នុងករណីនេះ គឺថែមទាំងជាគោលដៅដ៏សំខាន់ នៃដំណោះស្រាយសន្តិភាពរួម នៅទីក្រុងប៉ារីស និងលទ្ធផលនៃបំណងប្រាថ្នាដ៏ទទូចរបស់ជនភៀសខ្លួន ដែលចង់វិលត្រឡប់មកកាន់មាតុភូមិរបស់គេវិញ ដូចដែលបានបញ្ជាក់ដោយអ្នកសង្កេតការណ៍ ដែលបានតាមដានយ៉ាងខ្លាំងក្លានូវដំណាក់កាលត្រៀមនិងដំណើរការនៃប្រតិបត្តិការនេះ។

SOPHEAP. R~~ITH~~Y: RITHY

រហូតមកទល់ថ្ងៃទី ១៨ កុម្ភៈ ១៩៩៣ នេះ ជនកម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ក្រោមកម្មវិធីរបស់ឧត្តមស្នងការ អង្គការសហប្រជាជាតិ សំរាប់ជនភៀសខ្លួន ហៅកាត់ថា [ UNHCR] មានចំនួន ៣០០,០០០ នាក់ហើយ គឺជាង ៩០% នៃជនទាំងនេះ ដែលមកពីជំរំទាំង ៧ តាមព្រំដែនខ្មែរ-ថៃ។ មានជនភៀសខ្លួនចំនួន ២០០០ នាក់ មកពីជំរំនៅប្រទេសឥណ្ឌូណេស៊ី វៀតណាម និងម៉ាឡេស៊ី ក៏បានវិលត្រឡប់មកវិញ តាមកម្មវិធីនេះដែរ ។ ហើយជនភៀសខ្លួនខ្មែរទាំងអស់ ដែលរស់នៅក្នុងជំរំតាមបណ្តោយព្រំដែនខ្មែរ-ថៃនោះ និងត្រូវធ្វើមាតុភូមិនិវត្តន៍ ឲ្យបានមុនខែមីនា។